# ការសម្ភាសរបស់អ៊ី អោក ឆេងហាន

កៈអ្នកសម្ភាសឈ្មោះ កុយសុភី ខៈអ្នកត្រូវគេសម្ភាសឈ្មោះអោក ឆេងហាន

## ពត៌មានសង្ខេបរបស់អោក ឆេងហាន

អ៊ី អោក ឆេងហាន មានអាយុ៦០ឆ្នាំ កើតនៅឆ្នាំកោរ ។ មានទីលំនៅ នៅភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។អ៊ីបានរៀននៅសាលាវត្ត ក្នុងស្រុកកំណើត អ៊ីមានបងប្អូន៦នាក់តែមានបងប្អូន១នាក់បានស្លាប់នៅក្នុងជំនាន់ប៉ុលពតដោយគេយកនៅសម្លាប់ ក្រោយពេលដាច់មកអ៊ីបានរៀបការនៅអាយុ១៨ឆ្នាំ ដោយធ្វើពិធីសែនបន្តិចបន្តួចដោយមានអញ្ជើញញាតិមិត្តបន្តិចបន្តិចមកចូលរួមក្នុងពិធី ក្រោយមកមានកូន៧នាក់ក្នុងបន្ទុក ដោយបានប្រកបមុខរបរធ្វើស្រែចំការតរហូតមកដល់សព្វថ្ងៃជាមួយនិងស្វាមី តែមកដល់ពេលឥឡូវនេះអ៊ីបានឈឺចឹងអត់បានជួយការងារស្រែចំការស្វាមីច្រើននោះទេ។

កៈ ចាសជាដំបូងជម្រាបសួរអ៊ី!

ខៈ ចាស!

កៈ សព្វថ្ងៃអ៊ីសុខសប្បាយទេអ៊ី?

ខៈ សុខសប្បាយទេ!

កៈ ចាស!

ខៈ ប៉ុន្តែចេះតែឈឺ!

កៈ ឈឺដែរ!

ខៈ ឈឺដែរ ឈឺដៃឈឺជើង ឈឺចង្កេះ ឈឺចង្កង់

កៈ ចេះតែឈឺ មានបន្តិចៗទៅហើយ!

ខ៖ចាស!

ក៖ ចឹងខ្ញុំឈ្មោះកុយ សុភីបានមកធ្វើការសម្ភាសនៅឆ្នាំចសំរិតស័ក ពុទ្ធសារាជ ២៥៦២ ខែមកសិរ ត្រូវនឹង៨កើត ត្រូវនឹងថ្ងៃសៅរ៍ ទី១៥ ខែធ្នូ ឆ្នាំ២០១៨។
ចុះនាមត្រកូលនិងនាមខ្លួនរបស់អ៊ីមានឈ្មោះអ្វី?

ខ៖ ទាំងនាមត្រកូលខ្ញុំ ឈ្មោះ អោកឆេងហាន។

ក៖ ចាស!ឈ្មោះហ្នឹងអ្នកណាជាអ្នកដាក់ឈ្មោះអោយ?

ខ៖ ម្ដាយឪពុក!

ក៖ ចាសចុះឈ្មោះហ្នឹងមានអត្ថន័យយ៉ាងម៉េច?

ខ៖ ( អ៊ីក្រហែម) អត់ដឹង!

ក៖ អត់ដឹងទេ!

ខ៖ វាភ្លេចបាត់អស់ទៅ!

ក៖ ចឹងអ៊ីមានឈ្មោះហៅក្រៅ១នាក់ទៀតដេស?

ខ៖ អត់ដឹងនោះទេ មានតែ១ហ្នឹងនោះទេចាស។

ក៖ អ៊ីមានសញ្ញាតិជាអ្វី?

ខ៖ សញ្ជាតិខ្មែរ!

ក៖ ចាស! អ៊ីកើតនៅថ្ងៃ ខែ ឆ្នាំណា?

ខ៖ នៅឆ្នាំកោរ!

ក៖ ឆ្នាំកោរ !

ខ៖ ចាស!

ក៖ តើបច្ចុប្បន្នអាយុប៉ុន្មានហើយ?

ខ៖ អាយុបាន៦០!

ក៖ ចាសតើទីលំនៅបច្ចុប្បន្ននៅឯណា?

ខ៖ នៅព្រៃទទឹង!

ក៖ នៅព្រៃទទឹង?

ខ៖ ចាស

ក៖ ឃុំ?

ខ៖ ឃុំ ជ្រៃវៀនហោស?

ក៖ ចាស! ហើយស្រុក?

ខ៖ ស្រុកព្រៃឈរ!

ក៖ ចុះខេត្ត?

ខ៖ ខេត្តកំពង់ចាម!

ក៖ចាស នាមត្រកូលនិងនាមខ្លួនរបស់ឪពុកអ៊ី តើឈ្មោះអ្វី?

ខ៖ ឈ្មោះ គីម អោក!

ក៖ ចាស! ចឹងសព្វថ្ងៃគាត់នៅរស់?

ខ៖ ងាប់ហើយ

ក៖ កាលគាត់ស្លាប់នុងនៅអាយុប៉ុន្មាន?

ខ៖ កាលគាត់ស្លាប់នុងនៅអាយុ៧៩។

ក៖ ៧៩! ចឹងដឹងថាគាត់បានរៀនដល់ថ្នាក់ទីប៉ុន្មានដែរអ៊ី?

ខ៖ ហែស! កាលនុងដឹងថាគាត់រៀននៅសាលាវត្ត។

កៈ ចឹងគាត់មានចេះអក្សរវត្តដែសអ៊ី?

ខៈ ចេះណា គាត់ចេះអក្សរវត្ត!

កៈ ចាសចុះគាត់មានអត្តចរិតយ៉ាងម៉េចដូចម្ដេច?

ខៈ អត្តចរិតរបស់គាត់ដូចជាធម្មតា

កៈ ចាសគាត់មានមុខរបរធ្វើអ្វី?

ខៈ ធ្វើស្រែ ធ្វើចំការ!

កៈ តើទីកន្លែងកំណើតរបស់គាត់កើតនៅក្នុងភូមិ?

ខៈ ភូមិព្រៃកក្របៅ! ឃុំព្រៃកក្របៅ!

កៈ ហើយចុះស្រុក?

ខៈ ស្រុកកងមាស ខេត្តកំពង់ចាម!

កៈ ចាស! បងប្អូនខាងឪពុកអ៊ីមានចំនួន?

ខៈ ៥នាក់!

កៈ តើបងទី១មានឈ្មោះអ្វី?

ខៈ បងទី១ឈ្មោះតា ថូយ! អ៊ី គីម ថូយ!

កៈ ចាសភេទ?

ខៈ ភេទប្រុស!

កៈ ចាសទី២?

ខៈ ទី២គីម ថាន!

កៈ ភេទ?

ខ៖ ប្រុស!

ក៖ ទី៣?

ខ៖ ទី៣គឺមអោក!

ក៖ ទី៤?

ខ៖ ទី៤គឺមចាន់!

ក៖ ភេទ?

ខ៖ ភេទប្រុសដែរ!

ក៖ ទី៥?

ខ៖ ទី៥គឺមញ៉ឹប!ភេទស្រី!

ក៖ ភេទស្រី! អឺ!នាមត្រកូលនិងនាមខ្លួនខាងម្ដាយអ៊ីតើមានឈ្មោះអ្វី?

ខ៖  ខាងម្ដាយហ្វូត ហ៊ន

ក៖ ចាសអឺ! គាត់សព្វថ្ងៃនៅរស់ដេស?

ខ៖ នៅរស់តែសព្វថ្ងៃចាស់ជរា!

ក៖ អូ៎ គាត់ហ្នឹងចាស់ជរាហើយ! ចឹងតើគាត់បានរៀនដល់ថ្នាក់ទីប៉ុន្នានដែរ?

ខ៖ អត់មានបានរៀននោះទេ

ក៖ អត់សោះណំ?

ខ៖ ចាស!

ក៖ គាត់មានអត្តចរិត?

ខ៖ អត្តចរិតស្លូតបូត!

កៈ គាត់មានមុខរបរធ្វើអ្វី?

ខៈ ធ្វើស្រែធ្វើចំការកាលពីមុនឡើយ!

កៈ ចាស! ចឹងចុះទីកន្លែងកំណើតរបស់គាត់កើត?

ខៈ នៅព្រៃកក្របៅ!

កៈ ចឹងនៅព្រៃកក្របៅហ្នឹងដែរហោស?

ខៈ ចាស!

កៈ
ហើយចឹងតើគាត់បានចូលជាភ្ជាប់សាច់ឈាមជាមួយនឹងម្ដាយឪពុកអីតើជាប់សាច់ឈាមឬក៏?

ខៈ ជាប់! ជាប់ជាជីដូនមួយ!

កៈ អូ! ហើយចឹងបងប្អូនបង្កើតរបស់ម្ដាយហ្នឹងណា តើមានចំនួនប៉ុន្មាននាក់?

ខៈ មាន៤នាក់!

កៈ ចាសបងទី១ឈ្មោះ?

ខៈ បងទី១ឈ្មោះ ហួតស៊ីម!

កៈ ចុះភេទ?

ខៈ ភេទប្រុស!

កៈ ទី២ឈ្មោះហួតលីម ភេទប្រុសដែរ!

ខៈ ចាស!

កៈ ចុះទី៣?

ខៈ ទី៣អូ យាយលៀបបងគេ!

កៈ ចឹងហួតលៀបចឹងហេស?

ខៈ ចាសហួតលៀប គាត់បងគេទី១ ស្រី។

កៈ ចាសហើយបន្ទាប់មកទី២?

ខៈ ទី២ ហួតស៊ីម!

កៈ ចាសទី៣?

ខៈ ទី៣ហួតលីម ទី៤ហួត ឈៀង!

កៈ អូ តាឈៀង!

ខៈ ចាស! ដល់ពេលទី៥ ហួតផ័ន!

កៈ ចឹងដល់ពេលយាយពៅគេនេស?

ខៈ ពៅគេ!

កៈ អ៊ីមានបងប្អូនចំនួនប៉ុន្មាននាក់?

ខៈ បងប្អូន៥នាក់!

កៈ ចាស!ទី១

ខៈ ៦នាក់នុង ងាប់១

កៈ ចឹងរាប់ទាំងស្លាប់នុងដែរ។

ខៈ ព្រោះស្លាប់នៅជំនាន់ប៉ុលពត!

កៈ គេយកទៅវ៉ៃចោល?

ខៈ ចាស

កៈ ចឹងបងទី១ឈ្មោះអ្វី?

ខ៖ ឈ្មោះ អៀក ឆេងវ៉ាន!

ក៖ទី២?

ខ៖ ទី២អៀក ឆេងហាន!

ក៖ ចាសទី៣?

ខ៖ ទី៣អោក ឆេងហ៊ាង។

ក៖ទី៤?

ខ៖ ទី៤អោក ឆេងគៀង!

ក៖ ទី៥?

ខ៖ ទី៥អោក យាយសៀង!

ក៖ ចាស!

ខ៖ ហើយដល់ពេល១ទៀតទី៦អោកម៉េង។

ក៖ ចាស!

ខ៖ អើ!ថាភ្លេចៗម៉េន ភ្លេច១ ហាសៗ

ក៖ ចាស! អ៊ីបានរៀបអាពាហ៏ពិពាហ៏នៅក្នុងឆ្នាំណា?

ខ៖ ឆ្នាំដាច់!

ក៖ឆ្នាំដាច់!

ខ៖ មិនដឹងថាឆ្នាំអីនោះទេនេះ!

ក៖ ដាច់ឆ្នាំ៧៩នុង!

ខ៖ មិនដឹងថាដាច់នៅឆ្នាំអីនោះទេ!

កៈ ដាច់នៅឆ្នាំ៧៩!

ខៈ អូចឹងហ៎ចឹងនៅឆ្នាំ៧៩នុងហើយ!

កៈ ចឹងអ៊ីកាលពេលរបបសាធារណៈរដ្ឋកម្ពុជា
ដូចថាពេលទើបតែដាច់នុងមិនទាន់រីកចំរើនអីនោះទេ!

ខៈ នុងៗវាខ្វះខាត បាទដែទទេ!

កៈ ចាស! ចឹងកាលការនុងនៅអាយុប៉ុន្មាន?

ខៈ កាលការនុងនៅអាយុ១៨ហើយ!

កៈ ១៨ ចឹងអ៊ីបានចូលសិក្សានៅថ្នាក់ទីប៉ុន្មាន?

ខៈ អូ! រៀនបានត្រឹមតែថ្នាក់ទី១ ហើយបាតុកម្ម រៀននៅសាលាវត្ត។

កៈ អូ...

ខៈ នៅវត្តត្រពាំងព្រះនុងណា!

កៈ ចា

ខៈហើយដល់ពេលគេបាតុកម្មនៅជិតវត្តនុងរត់មក គ្មានបានរៀនអីនោះទេ អត់ចេះទេ។

កៈ ចឹងអ៊ីសព្វថ្ងៃកាន់សាសនា?

ខៈ ព្រះពុទ្ធ

កៈ ចាសចឹងកាលអ៊ីនៅនុងអត់ទាន់មានមុខរបរអ្វីនោះទេ
ព្រោះអីទើបតែបានជាប់ថ្នាក់ដំបូងណាចាស?

ខៈ ចាសទើបតែបានរៀនថ្នាក់ដំបូង!

កៈ ហើយទៅនាមត្រកូលខាងស្វាមីរបស់អ៊ីវិញតើឈ្មោះអ្វី?

ខៈ ឈ្មោះ អោក យុនដែរ។

កៈ ចឹង!

ខៈ ចាស!

កៈ កើតនៅថ្ងៃខែឆ្នាំណាដែរ?

ខៈ ឆ្នាំការ!

កៈ ហើយមកដល់ពេលឥឡូវគាត់មានអាយុបានប៉ុន្មានដែរ?

ខៈ អាយុប៉ុន្មាននោះទេ ដូចជា៦២!

កៈ ចឹង!

ខៈចា

កៈ គាត់បានសិក្សាបានដល់ថ្នាក់ទីប៉ុន្មាន?

ខៈ អូ...!កាលនុងនៅវត្ត!

កៈ នៅវត្ត!

ខៈ នៅវត្ត

កៈ ចឹងអត់បានរៀនដែរ!

ខៈ អត់បានរៀនដែរ អត់មានបានបួសផង បានបន្តិចៗ។

កៈ ចាស!ចឹងគាត់មានសញ្ជាតិជា?

ខៈ ខ្មែរ!

កៈ ចាស! ហើយទៅកាលនុងមុខរបររបស់គាត់ អត់មានធ្វើអីនោះទេណំនៅកាលនុងនៅវត្ត?

ខៈ មានធ្វើស្រែចំការដល់មកឥឡូវនុងណា!

កៈ ចឹង!

ខ៖ ចាស!

ក៖ ហើយចុះអត្តចរិតរបស់គាត់យ៉ាងម៉េចដែរ?

ខ៖ អត្តចរិតស្លូតបូតធ្វើស្រែធ្វើចំការ?

ក៖ ទីលំនៅស្រុកកំណើតរបស់គាត់?

ខ៖ នៅចំការឪឡឹក!

ក៖ ភូមិចំការឪឡឹកចឹងហោស?

ខ៖ភូមិចំការឪឡឹកហឹម

ក៖ ឃុំ?

ខ៖ ឃុំព្រៃកក្របៅ ស្រុកកងមាសដែរ ខេត្តកំពង់ចាម។

ក៖
ចាសចឹងតើមូលហេតុអ្វីបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគាត់តើដោយសារតែមូលហេតុអ្វី?

ខ៖ ដោយសារអ្វី ដោយសារតែគេឃើញគេស្រលាញ់!

ក៖ ចឹងហោស?

ខ៖ ចាស!

ក៖ ចឹងហើយគេចូលមក!

ខ៖គេចូលបងស្ដីដណ្ដឹង!

ក៖ គេចូលមកស្ដីដណ្ដឹងតាមប្រពៃណីទៅ!

ខ៖ ចាស!

ក៖ ចឹងអីបានប្រគាប់ថ្លៃទឹកដោះបានប៉ុន្មានកាលនុង?

ខ៖ អត់នោះទេ អត់មានបានបង្គាប់នោះទេ ពេលនុង ព្រោះអីទើបតែដាច់រៀបថ្មីៗ

ក៖ រួចចឹងធ្វើយ៉ាងម៉េចដែរចឹង អត់បានលុយអីយើងរៀបចំពិធី?

ខ៖ អត់ទេ!

ក៖ ចឹងកាលនុងធ្វើលក្ខខណៈតូចអីដូចជាសែន?

ខ៖ ចាស!នុងហើយ

ក៖ ចឹង!

ខ៖ អើ!១ព្រឹកចឹងទៅ បានប្រាប់ភ្ញៀវទៅ បាច ផ្កាស្លាអីចឹងទៅ។

ក៖ អូចឹងហោស!

ខ៖ ចាស!

ក៖ ដល់ពេលអ៊ីបានរៀបអាពាហ៍ពិពាហ៍ហើយ បានចាប់ដៃគ្នាហើយ
កសាងអនាគតហើយនេស?

ខ៖ ចាស!

ក៖ ហើយតើអ៊ីបានប្រកបមុខរបរអ្វី?

ខ៖ធ្វើស្រែចំការ!

ក៖ ហឹម! ដីស្រែចំការនុង បានឪពុកម្តាយអោយដីឬយ៉ាងម៉េចដែរ?

ខ៖ បានឪពុកម្តាយអោយ! នៅកាលនុងបានគេចែករបប។

ក៖ គេចែករបបអោយហ៎?

ខ៖ ចាស!

ក៖ ចឹងដីនុងបានក្បាលប៉ុន្មានហើយបណ្តោយប៉ុន្មានដែរអ៊ី?

ខ៖ ហឹម ដីនុងបាននេះបន្តិចនោះបន្តិចចឹងណា! តែបន្តិចនុងហ៎
នៅឯខាងលិចនោះក្បាលបន្តិចប្រហែល១៥ម៉ែត្រ បណ្តោយ២០០។

ក៖ អូ!...ចាសចឹងបានអីធ្វើរហូត ចឹងបានរយៈពេលប៉ុន្មានបានជាអីបានមានបុត្របុត្រាអី?

ខ៖ អឹម! ដាច់មកប្រហែលជាបាន៧ទៅ៨ឆ្នាំអីហើយ!

ក៖ ហើយទៅអឹមានការនុង តើបានមានបុត្រាបុត្រីណា?

ខ៖ កាលនុងប្រហែលជាបាន៤ទៅ៥ឆ្នាំអីនោះបានមានចាស!

ក៖ អូចឹងបាននៅយូរណ៎!

ខ៖ ចាស!

ក៖អូចាស! ចឹងអីតាំងពីរៀបការមកអីនៅតែធ្វើស្រែរហូត៧ទៅ៨ហ្នឹង?

ខ៖ ធ្វើស្រែរហូតមកទាល់តែពេលឥឡូវហ្នឹង?

ក៖ ចឹងឥឡូវហ្នឹងនៅតែធ្វើដែរ?

ខ៖ នៅធ្វើដែរ ប៉ុន្តែមិនដែលបានទៅនោះទេ ឈឺជើង ឈឺដៃ ដើរទៅមិនរួចនោះទេ
បានតែតានោះធ្វើ២នាក់កូនចឹងទៅ ឈឺក្បាលជង្គង់ដើរមិនចង់រួច។

ក៖ ចឹង!

ខ៖ ចាស

ក៖ ចឹងដូចជាកូនទី១មានឈ្មោះអ្វី?

ខ៖ កូនទី១ឈ្មោះ អោក ឆេង អាន!

ក៖ ស្រីហោស?

ខ៖ ស្រី!

ក៖ តើគាត់មានគូស្រករនៅ?

ខ៖ មានហើយ!

ក៖មានកូន៣នាក់ហើយ!

ខ៖ កូនបានធំៗហើយ!

ក៖ ចឹងកូនប្រសារមានឈ្មោះអ្វី?

ខ៖ កូនប្រសារមានឈ្មោះ ថេន ធឿន!

ក៖ ចាស! ចុះគាត់២នាក់ហ្នឹង តើគាត់ប្រកបមុខរបរធ្វើអ្វី?

ខ៖ ទៅនៅឯភ្នំពេញឯណោះ ទៅធ្វើការសំណង់អីនោះ!

ក៖ ហ្នឹងប្ដី! ហើយចុះប្រពន្ធទៅធ្វើអីដែរ?

ខ៖ ទាំង២នាក់ហ្នឹងទៅជាមួយគ្នា!

ក៖ យ៉ាងម៉េចដែរ ធ្វើការជាមួយគ្នា?

ខ៖ ធ្វើជាមួយនឹងគ្នា!

ក៖ ចុះកូនអោយអ៊ីមើល?

ខ៖ បើមីធំនោះ ខ្ញុំមើល!

ក៖ ចឹងគេធំហើយគេបែកផ្ទះអស់ហើយនេស? តើគេធ្វើផ្ទះបែកហ៎អ៊ី?

ខ៖ ផ្ទះនោះតូចទេធ្វើ តែមកដល់ពេលឥឡូវនេះវាពុកវាអីអស់ទៅហើយ។

ក៖ ធ្វើនៅក្បែរនុង?

ខ៖ នៅក្បែរនុង

ក៖ ចាស! ហ៎ស!

ខ៖ វាបានកូន៣នាក់!

កៈ ចឹងបានកូន៣នាក់ហើយ!

ខៈ ចាស!បានកូន៣នាក់ ហើយ១នោះវាធ្វើតភ្លើងតអី គេ
ហើយដល់ពេលមីពៅតូចនោះនៅរៀន ។

កៈរៀនបានដល់ថ្នាក់ទីប៉ុន្មានដែរកូនពៅនុង?

ខៈ ត្រឹមថ្នាក់ទី១ហាស!ៗ

កៈ ឥឡូវកូនទី២ឈ្មោះអីដែរអឺ?

ខៈ ឈ្មោះ ធាង វួចលី!

កៈ ចុះមកថ្ងៃខែឆ្នាំកំណើតរបស់គាត់កើត?

ខៈ ឆ្នាំថោះ?

កៈ ឆ្នាំថោះ?

ខៈ ចាស!

កៈ ហើយមកដល់ពេលឥឡូវនេះអាយុប៉ុន្មានហើយ?

ខៈ អាយុ១៩ហើយ!

កៈ ចឹងអាយុ១៩ហើយ?

ខៈ ហ្នឹងហើយ!

កៈ ចុះមកដល់ពេលឥឡូវហ្នឹង គាត់មានអាយុប៉ុន្មាន?

ខៈ ១២!ប្រឡងជាប់ហើយ

កៈ ហើយចឹងបានរៀនតទៀតដេស?

ខៈ រៀនតទៀតបាន១ឆ្នាំ!

កះចាសចឹងរៀនបានផ្នែកអីដែរអី?

ខះ អត់មានដឹងថារៀនខាងផ្នែកអីនោះទេ!

កះ កូនទៅរៀនបាន១ឆ្នាំហើយ!

ខះ ចាស!

កះ ចាស!

ខះ ហើយនៅអាប្រុស១គេនៅតភ្លើង

កះ ឈ្មោះអីអាប្រុសនុង?

ខះ ឈ្មោះ ធឿនសុនី!

កះ ចាសទៅតភ្លើងចុះឈប់រៀនហើយ?

ខះ ឈប់រៀនហើយ!

កះ បានត្រឹមថ្នាក់ទីប៉ុន្មាន?

ខះ ថ្នាក់ទី៩!

កះ ចាស!

ខះ បានថ្នាក់ទី៩ចូលថ្នាក់ទី១០នុងណា!

កះហើយចឹងទៅឈប់បានឥឡូវទៅធ្វើការ តភ្លើងនុងគេអោយប្រាក់ខែ បាន១ខែប៉ុន្មានដែរ?

ខះ អត់ដឹងដែរ!

កះ ចុះអត់មានដែរផ្ញើមកអីនោះទេ?

ខះ អត់នោះទេ! គឺវានៅនុងហើយ

កះ អូ...!ចាសសួរនេះ សួរកូនរបស់អីមិនមែនចៅនោះទេណា!

ខ៖ ចៅហេស!

ក៖ អត់សួរចៅនោះទេ សួរកូនណា!

ខ៖ ហឹម! សួរកូនទេ( គាត់ស្មានតែសួរចៅ)

ក៖ ចាសកូនអ៊ីមានចំនួនប៉ុន្មានចឹងទៅណា?

ខ៖ មាន៧នាក់!

ក៖ ៧នាក់ចឹង

ខ៖ ៧នាក់ហាសៗ

ក៖ ចឹងកូនទី១?

ខ៖ទី១ឈ្មោះ អោក ឆេងអាន។

ក៖ ចាសគាត់មានស្វាមីហើយ

ខ៖ មានហើយ

ក៖ ចាសបានកូន៣នាក់ហើយចឹងអ៊ីមានចៅបាន៣នាក់ហើយនេះ ចុះមកដល់កូនទី២?

ខ៖ ទី២ឈ្មោះ យុន សាន!

ក៖ យុនសាន! ចុះភេទរបស់គាត់?

ខ៖ ភេទប្រុស!

ក៖ ចាសគាត់បានរៀនត្រឹមថ្នាក់ទីប៉ុន្មាន?

ខ៖ថ្នាក់ទីប៉ុន្មាននោះទេ បានថ្នាក់ទី៧។

ក៖ ចាសហើយចុះដល់ពេលមកកូនទី៣?

ខ៖ ទី៣ យុនចំរើន!

កៈ ចាស! ចុះគាត់កើតនៅថ្ងៃខែឆ្នាំណា?

ខៈ ឆ្នាំជូត មើលអានុងឆ្នាំជូត

កៈ ចុះរៀនដល់ត្រឹមថ្នាក់ទីប៉ុន្មាន?

ខៈ ថ្នាក់ទី៧ដែរនុង ទៅរៀនបាននៅពាមជីកងនោះបានបន្តិច។

កៈ ចាស!ចឹងចុះនៅរៀនទាល់តែមកដល់ពេលឥឡូវនេះដេស?

ខៈ អត់ទេ! មកដល់ឥឡូវបានមានប្រពន្ធ!

កៈ អូចឹងបានមានប្រពន្ធហើយហេស?

ខៈ បានរៀបការបាន២ដងហើយ!

កៈ ចឹង!

ខៈ បានពីព្រៃវែងហើយបានលែងមក
ហើយបានមកការនៅភូមិចិននេះ១ទៀតនៅឯខ្លែងពណ៌ណា។

កៈ ចឹងនៅឯភូមិចិនហ្នឹងប្រពន្ធរបស់គាត់ឈ្មោះអ្វី?

ខៈប្រពន្ធឈ្មោះ ឈៀងដារ៉ា

កៈ ចឹងគាត់ទៅធ្វើការនុងទៅ បានឃើញគ្នាចឹងទៅក៏ចូលស្ដីដណ្ដឹងចឹងទៅណា?

ខៈ ហ្នឹងហើយ!

កៈ ចុះប្រពន្ធមុនមានកូនដេស?

ខៈ ប្រពន្ធមុនមានកូន១ ហើយប្រុសដែរ ដល់ពេលឥឡូវនេះមានកូនប្រុស១នាក់ទៀត។

កៈ ចាសមកដល់ពេលឥឡូវកូនអីទី៤?

ខៈ កូនទី៤ ឃុនម៉ាច!

ក៖ ភេទ?

ខ៖ភេទប្រុស!បានកូន២នាក់ហើយ កូនស្រី។

ក៖ ចឹងហ្នឹងតើគាត់បានរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ បានត្រឹមថ្នាក់ទី៦អីនុង

ក៖ ហើយប្រពន្ធរបស់គាត់នៅខាងណា?

ខ៖ ប្រពន្ធនៅខាងព្រែកក្របៅនេះដែរ។

ក៖ ហើយចឹងតើប្រពន្ធរបស់គាត់មានឈ្មោះ?

ខ៖ ប្រពន្ធឈ្មោះ សុគន្ធា។

ក៖ ចុះគាត់មានកូននៅ?

ខ៖ មានកូនបាន២នាក់ហើយ សុតតែស្រី!

ក៖ ចាសហើយចុះកូនអ៊ីទី៥?

ខ៖ កូនទី៥អ៊ី! យុន ផៃលីម

ក៖ ចាស គាត់កើតនៅក្នុងថ្ងៃខែឆ្នាំ?

ខ៖ មិនបានដឹងថាកើតនៅឆ្នាំអីនោះទេ ឆ្នាំមមែ។

ក៖ ចឹងគាត់បានរៀនត្រឹមថ្នាក់ទីប៉ុន្មាន?

ខ៖ កាលនុងវារៀនបានថ្នាក់ទី១០ បានទី១១។

ក៖ ចឹងក៏បានឈប់ត្រឹមនុងទៅណា?

ខ៖ ចាសហើយក៏រកស៊ីវិញទៅ!

ក៖ ចឹងតើគាត់មានគូរស្រករនៅ?

ខ៖ នៅ ការនៅខែ២ហ្នឹង!

ក៖ អូ!... ចឹងនៅខែ២ហ្នឹងបានរៀបការហើយណា?

ខ៖ ចាស!

ក៖ ចាសហើយចឹងតើគេនៅខាងណាដែលខាងប្រុស?

ខ៖ នៅឯខាងព្រៃវៀង អូនៅខាងសៀមរាបតែមិនដល់សៀមរាបនោះទេ
ទៅពីស្ទោងបន្តិចទៅ។

ក៖ ឆ្ងាយណាស់!

ខ៖ ឆ្ងាយ!

ក៖ ចឹងពេលទៅធ្វើការចឹងទៅគាត់បានឃើញគ្នាចឹងហោស?

ខ៖ ហ្នឹងហើយទៅធ្វើថៅកុងឡាន ហើយក៏គេបានណែលនាំ!

ក៖ អូ...ចឹងគាត់បានគេណែនាំចឹងហោស?

ខ៖ គេណែនាំបាន បាន

ក៖ ចាសហើយចឹងតើគាត់ទៅធ្វើការបើកឡាននុងបាន១ខែប៉ុន្មានដែរ?

ខ៖ អត់ដឹងដែរមិនដឹងថា១ខែបានប៉ុន្មាននោះទេ
តែដឹងថាគេគិតជាជើងទៅ១ជើងបាន១០០០០០ចឹងទៅ ពីភ្នំពេញទៅសៀមរាប។

ក៖ ចឹងឡានអីគេ ឡានក្រុងឬក៏យ៉ាងម៉េច?

ខ៖ ឡានក្រុង ឡានដឹកទំនេញ!

ក៖ ចឹងឡានដឹងឥវ៉ាន់អី?

ខ៖ ហ្នឹងហើយ! ឡានដឹកឥវ៉ាន់យកទៅ ទៅសៀមរាប
ដល់ពេលចុះមកវិញបានដាក់អង្កយកទៅ។

កះ ចាសហើយចឹងដល់ពេលបន្ទាប់មកទៀត?

ខះ បន្ទាប់មកទៀតទី៦ហោស?

កះ ចាស!

ខះ ទី៦យុន ទ្រី!

កះ ចាសរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរហើយ?

ខះ រៀនទី១២ហើយតែថាមកដល់ពេលឥឡូវនេះបួសលោក!

កះ ចុះឆ្នាំ?

ខះ ឆ្នាំស្អីនោះទេនេះ! មើលរកនឹកសិន បើសិនជាច្រើនពេកនោះគឺភ្លេចអស់ហើយ ។

កះ ហើយចឹងភ្លេចក៏ភ្លេចទៅអ៊ី!ចុះកូនទី៧?

ខះ ទី៧ស្រីពុត! យុនស្រីពុត

កះ ចាសឆ្នាំគាត់ដែរ?

ខះ ឆ្នាំរោង!

កះ គាត់រៀនបានត្រឹមថ្នាក់ទីប៉ុន្មានហើយ?

ខះ ត្រឹមថ្នាក់ទី១២ជាប់ហើយ

កះ ទៅរៀននៅភ្នំពេញនុងឬក៏យ៉ាងម៉េចដែរ?

ខះ អត់មានបានរៀននោះទេ

កះ ចឹងឈប់ហើយ!

ខះ អត់មានលុយរៀនត ចឹងធ្វើការងាររោងចក្រ!

កះ ហឹម! អូ! ធ្វើការរោងចក្រនៅឯភ្នំពេញហ្នឹង?

ខ៖ នៅឯភ្នំពេញ ចិញ្ចឹមកូនរហូតទៅដល់៦ទៅ៧នាក់។

ក៖
ចាសអ៊ីចូលនិយាយអំពីការរកស៊ីចិញ្ចឹមគ្រួសារនិងចិញ្ចឹមកូនអីនុងដែលបានតាំងពីចាប់ដៃគ្នាមកតើមានការរកស៊ីអីដែរ និងជីវៈភាពយ៉ាងម៉េចខ្លះដែរអ៊ី?

ខ៖ ជីវៈភាពគ្រាន់បានម៉ាហូបៗខ្លះបន្តិចបន្តួច!

ក៖ ហឹសហើយមានប្រកបមុខរបរអ្វីខ្លះក្រៅពីហ្នឹងទៀតដេសអ៊ីទ្រាអី?

ខ៖ អត់នោះទេ!

ក៖ ចឹងមានខាងរកត្រីរកអីដេស?

ខ៖ កាលពីមុនមករកតែថាមកដល់ពេលឥឡូវនេះឈប់អស់ទៅហើយ ចាស់ៗអស់ទៅហើយខ្ជិលរក។

ក៖ ចឹងអ៊ីចូលនិយាយអំពី ជីវិតអ៊ីបានឆ្លងកាត់នៅរបបអ្វីខ្លះ?

ខ៖ របបប៉ុលពត!

ក៖ ចាសរបបនុងតើអ៊ីគេអោយអ៊ីធ្វើអ្វីខ្លះ?

ខ៖ អើយរែកដី!

ក៖ ហើយយ៉ាងម៉េចទៀត?

ខ៖ រែកដី ស្ទូង ដកអីចឹងនៅការដ្ឋានគេអោយយើងទៅ!

ក៖ គេអោយរែកនុងគេអោយអ៊ីរែកយ៉ាងម៉េច នៅក្នុង១នាក់ប៉ុន្មាន?

ខ៖ ៣ម៉ែត្រគីប

ក៖ ចឹង៣ម៉ែត្រគីបនុងរែកបានដែស?

ខ៖ រែកបានប្រឹងតែមែនទែនណា ១ថ្ងៃទាល់ល្ងាចណា។

កៈ អូ...បាន!

ខៈ វែកបានតែថាប្រឹង

កៈ ចឹងគេអោយអីហូបយ៉ាងម៉េចដែរម្ហូប?

ខៈ ម្ហូបវិញវាយ៉ាប់ម៉ែនទែននុងណា គេបានដាក់ដូចបង្គីប៉ុណ្ណោះ
ហើយដាក់អោយហូប១នាក់មានប្រធានក្រុមគេបានចែកចឹងទៅ។

កៈ ចាស!

ខៈ ហើយដល់ពេលម្ហូបគេនុងស៊ីអោយតែថាបានអោយតែរស់ៗចឹងទៅណា។

កៈហឹមចាស!

ខៈ ដល់ពេលទៅការដ្ឋានស្ទូងចឹងទៅមានល្អុងចឹងទៅត្រកួនអីចឹងទៅ
ស៊ីរាគអាចម៍ចង់ស្លាប់ហើយ។

កៈអឹម! ហើយចុកប្រហុកហោសអី?

ខៈ អើចុកប្រហុក ចុះកាលនុងវាមិនដែលបានប្រហុកស៊ីនោះ ដល់ពេលចុះមកក្រោម
គេអោយតែគ្រាប់ពោត ជូនអីបបរឡើងរាវចឹងទៅ ។

កៈអីនេស!
ដែលឃើញផ្ទាល់នឹងភ្នែកដែលគេថានៅរបបនុងគេយកមនុស្សទៅវ៉ៃចោលផ្ទាល់នឹងភ្នែក
នោះ?

ខៈ ឃើញ! ឃើញគេយកទៅវ៉ៃចោល ដឹកទៅទាំងឡាន ហើយជូនអីដឹកទៅទាំងរទេះគោទៅ។

កៈហឹម!

ខៈហើយគេបានដឹកយកទៅទាំងរទេះគោនៅសាលាកាលេសនុងណា ។

កៈចាស!

ខ៖ ហើយមានស្រការដូងនោះគេបានដឹកម៉ាឡានៗមិនដឹងថាយកពីណាមកនោះទេ យកមកឡើង១ឡានៗចឹង ហើយស្រែកឡើងរចែករចាតៗ ឡើងរាច់ឡើងដោងចឹងទៅណា ឡើងចែកចាតៗចឹង វារៃទំលាក់រន្ធដៅនៅកន្លែងនុង។

ក៖ ចាស!

ខ៖ នៅកាលនុងអញនៅពាមជីកងគេអោយនៅនុង ហើយធ្វើស្រែនៅកន្លែងសាលាកាលេសនុងណា។

ក៖ អូចាសធ្វើស្រែនុងហេសចាស!

ខ៖ គេអោយបោចស្មៅបោចអីចឹងទៅ ហើយស្ទូងស្រែនៅកន្លែងនុងចឹងទៅ។

ក៖ ចុះអីអោយទៅឯណាទៅ?

ខ៖ គេអោយទៅធ្វើស្រែនៅខាងលើចឹងទៅ ដល់ពេលរដូវវស្សាគេអោយចុះមកវិញទៅ ដល់ពេលចុះមកវិញចឹងទៅគេបានអោយចុះទៅភូមិព្រែកគុយព្រែកអី មិនដែលបាននៅក្នុងភូមិព្រែកក្របៅនោះទេ! ទៅខាងនោះ

ក៖ ចុះកាលអីពេលនុងមានអាយុប៉ុន្មាននៅក្នុងរបបប៉ុលពតនុង?

ខ៖ អូ…កាលនុងនៅ១៨ឆ្នាំ

ក៖ អូ…ចឹងកាលនុងកំពង់តែពេញកំលាំងណេស?

ខ៖ អើ!កំពុងតែពេញកំលាំង! ប្រឹងនោះប្រឹងដល់ហើយកំពង់តែរែកដី ហើយមានប្រធានកងរបស់គេនោះ វាបានដេញ ស្រែកដាក់កាចៃ គ្រោកឡើងអស់ហើយឡើងវីរុក ហើយដល់ពេលអ្នកខ្លះវាងងុយដេកវា វាទៅច្រកនៅក្រោមដីដែលគេចាំងចេះមក ហើយដល់ស្រាប់តែជីនុងវាបាក់ចេះមកក៏បាក់ស្រឹបងាប់បាត់ទៅណា។

ក៖ អ៊ូ!…

ខ៖ នៅខាងភូមិថ្មី!

កៈ ១នាក់នុង

ខៈ អឹម ១នាក់នុង ងាប់ទៅបានដឹកយកមក!

កៈ ឯងុយពេកអ៊ូចាស

ខៈ អឺ ម៉ោង១២ ហើយវាធ្វើការយ៉ាប់ឡើងរាល់តែថ្ងៃ។

កៈ ចាស!

ខៈ ហើយដេកមិនឆ្អែកទៀតវាបានភ្លេចអស់ទៅហើយ ! គ្នាឯងគ្នាគេ វាបានភ្លេចអស់ទៅហើយ ស៊ីបាយវាស់វែកនុងណា វាគ្មានបានវែកធំៗចឹងនោះទេ វែកគេតូច បាន១វែកតូចៗ១នាក់។

កៈ ចឹងគេដាក់ក្នុង១របបអត់មានវែកទៅគេអោយយើងហូបអីៗទៀតដេស?

ខៈ គ្មាននោះទេ គ្មានបានត្រីប្រឡាក់ស្មោរអី!

កៈ ចឹងសម្លនុងគេហៅថាសម្លអីគេអឺ?

ខៈ សម្លម្ជូរអីនុង ម្ជូរត្រកួនគ្មានបានអីស៊ីឆ្ងាញ់!

កៈចឹងអឺដូចថាបានបែកពីម្ដាយឪពុកបងប្អូនពេលនឹកចឹងតើគេមានបានអោយអឺមកលេង?

ខៈ គេមិនអោមកនោះទេ! ទាល់តែថាយើងមកនៅជិតចឹងទៅយើងសុំ
ខ្សិបសុំប្រធានក្រុមអីនៅនុងចឹងទៅ មកលេងមួយភ្លេច
ហើយដល់ពេលមកនុងអត់មានអោយគេដឹងទៀត លួចលាក់
យ៉ាប់មែនទែននុងណាកាលនុងជំនាន់ប៉ុលពតនុងណា។

កៈ វេទនា! ចុះយ៉ាងម៉េចទៀត អឺគេបានអោយអឺបានធ្វើអ្វីទៀត
តើមានដែលជួបប្រទះប្រធានកងគេធ្វើបាបអីដេស?

ខៈ អត់អីដែរ!

កៈ អត់អីទេ!

ខៈ អឺ! ឃើញតែគេ!

ក៖ ចឹងយើងធ្វើការចេះតែមានកំលាំងបានចឹងទៅនេស?

ខ៖ ហ្នឹងហើយមិនមែនចេះតែរែជំនោះទេ!

ក៖ ចឹងកាលនុងអីរែកដីឡើងដល់៣ម៉ែត្រគីបនោះ

ខ៖ អឺ! ប្រឹងណា

ក៖ កាប់អឺ! រែកផង?

ខ៖ រែកផង តែអត់នោះទេ ២នាក់ ១នាក់អ្នកកាប់ហើយ១នាក់ទៀតអ្នករែក។

ក៖ អូ!....

ខ៖ ឡើងទំនប់ហោស ហើយដល់ពេលអឺអ្នករែក! អើអ្នករែក ហើយផ្លាស់ប្តូរគ្នា
១នាក់រែកមួយដងម្នាក់។

ក៖ ចាស!

ខ៖ ប្រគី២ផ្លូប

ក៖ ហើយកាលអឺនុងគេអោយរែកលីនៅឯខាងលើនុងគេហៅកន្លែងនុងអ្វីគេ?

ខ៖ ទួលគយូ នៅខាងព្រៃកចា ទំនុបនុងខ្ពស់ណាស់ទាល់តែរែកប្រឈិត អឹមចឹងទៅ
ឡើងប្រឈិត ហើយបើសិនជាឡើងត្រង់ចោទណាស់ ហើយទៅគេចាក់កាវាសអី។

ក៖ អូ...

ខ៖ ហើយដល់ពេលចាមអីបណ្តើរគ្នាយកទៅវៃចោល ! (គាត់និយាយខាងក្រៅថា
តើបានអឺបានស្វាយអូអរគុណ!) ចាមនុងអោយយើងអ្នកចាស់ៗហ្នឹងនាំចាមនុងមក ភរគ្នាថា
ផ្លាស់ទីកន្លែងផ្លាស់ទីលំនៅមកធ្វើការនៅកន្លែងទំនប់នុង រួចទៅល្បិចវាយកទៅវៃចោលណា
ហើយប្រធានគេថា មានមនុស្សហើយមិនចេះប្រើទុកអោយខ្ញុំប្រើ កុំយកវៃចោលចឹង
ចឹងទៅបានគ្នាទៅ
ហើយអ្នកខ្លះទៅវាភ័យគ្រាន់តែថាគេយកវាទៅវៃចោលចឹងវាបានរត់គេញទៅចូលនៅក្នុងព្រៃ
អីចឹងទៅណា ធ្វើបាបគ្នាដល់ហើយចាម។

កៈ ចាស អ៊ីដឹងអំពីដូចថាមានគូស្រករមក
ហើយមានកូនចៅហើយតើអ៊ីមានធ្វើបានផ្លូវចិត្តជាមួយនឹងទ្រាដេសតើទ្រាមានដែលបានធ្វើបានផ្លូវចិត្ត?

ខៈ អត់ទេ!

កៈ អត់ស្រួលទេ!

ខៈ ចាសស្រួលទេ!

កៈ ចឹងជាមួយនឹងកូនអ៊ីក៏ស្រួលដែរ?

ខៈ ចាស គ្រាន់តែថាខ្ញុំនេះគ្មានបានទៅធ្វើការអីកើតនោះទេ ទៅតែគាត់នុង
ដល់ពេលកូនខ្ញុំអីនុងនៅតែផ្ទះនុង

កៈ ចាស!តើអ៊ី តើជីតាជីដូនអីនុង
តើមានដែលបានដំណើរនិយាយប្រាប់អំពីជីវៈភាពគ្រួសាររបស់គាត់តាំងពីសម័យដើមមកកាលរស់នៅពេលនុងយ៉ាងម៉េចដែរ?

ខៈ
គាត់ថាលំបាកណាស់កាលនៅក្នុងជំនាន់របស់គាត់ពេលនុងគេចាប់ជំរិតមនុស្សចឹងចាប់ជំរិតនុងនៅមិនបាននោះទេដល់ពេលយប់ឡើងវាបានចាប់យកមកភ្លន់អីអស់ហើយ
ស្តាយមុងស្តាយភួយចុះហើយ វាភ្លន់គាត់យកទៅអស់រលីង១ដង។

កៈ ចា!

ខៈ ហើយទូដែកនុងវាបានកាប់យកទៅអស់!

កៈ ព្រោះឃាយនៅរត់ពួន!

ខៈ រត់ពួនឡើងទៅ!

កៈ ហ្នឹងហើយអស់រលើងវាយកទៅ
របស់គាត់កាលនៅខាងស្រុករបស់គាត់នៅឯព្រៃកកនៅចំការឪឡឹកនុងណាថាគេចាប់ជំរិតមនុស្ស។

កៈ ចាសចាប់ជំរិតនុងនៅមិនបាននោះទេ វាបានមកភ្លន់មកអីដល់ពេលព្រលប់មក
ទៅដេកគុម្ពចេកអស់ហើយ ស្ពាយមុងស្ពាយភួយចុះហើយ។

កៈ អូ…

ខៈ វាភ្លន់របស់គាត់យកអស់រលីង១ដង ទូដែកនុងប្រថៅ ហើយវាយកទៅកាប់ចឹងយកអស់។

កៈ ចឹងយាយនៅតែរត់ពួននុងហើយ!

ខៈ ចាស
ហើយស្អីៗនុងវាយកទៅរលីងទាំងក្រមាទាំងស្អីៗនុងអស់រលីងតាំងពីភួយតាំងពីក្រមាអីនុងគឺវាបានយកទៅអស់ហើយ។

កៈ ចាស!

ខៈ ហើយដល់ពេលតាំងពីប្រលប់ឡើងគឺដេកដីចុះដេកដីហើយ។

កៈពិបាកណាស់!

ខៈ ហើយដល់ពេលព្រឹកប្រលប់ឡើងចុះដេកនៅដី ហើយ។

កៈ ពិបាកណាស់

ខៈ ជំនាន់អីកាលនុងលំបាកណាស់
មិនដឹងថានៅជំនាន់អីកាលនុងដូចជាជំនាន់បារាំងហោសកាលនុងឬក៏ស្អី?

កៈ មិនដឹងដែរ!

ខៈអើមិនដឹងថាជំនាន់អីលឺសូរតែថាគាត់និយាយចឹង ។

កៈ ចឹងតែប៉ុណ្ណឹងនោះទេហោស!

ខ៖ ចាស!

ក៖ ចឹងអ៊ីមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើដល់កូនចៅជំនាន់ក្រោយ?

ខ៖ មានពាក្យពេចន៍ផ្តាំដល់កូនចៅថ្នាំញៀនបំបាត់
កុំអោយមានណាវាលំបាកវេទនាណាស់កូនចៅ។

ក៖ ចាស!

ខ៖ កូនចៅរក្សាតាមប្រពៃណីខ្មែរ!

ក៖ ពីការរៀបអាពាហ៍ពិពាហ៍ចឹងហោសអ៊ី?

ខ៖ ហ្នឹងហើយ!

ក៖ អោយចេះថែរក្សាអ្វីទៀតអ៊ី?

ខ៖ អោយចេះថែរក្សាប្រពៃណីខ្មែរ

ក៖ ដូចជាអ្វី?

ខ៖ដូចជា...

ក៖ នំមិនធំជាងនាចឹងហោសអ៊ី?

ខ៖ អឺៗ នំកុំធំជាងនា ឥឡូវនេះតែថាកូនចៅរបស់ខ្ញុំនោះអត់នោះទេ។

ក៖ ចាសហើយអោយចេះគោរពអីគេអ៊ីចេះគោរពអី?

ខ៖ អឹម!!

ក៖ ចេះគោរពឪពុកម្តាយ អ្នកមានគុណ
ចេញទៅក្រៅចេះគោរពចាស់ព្រឹធិចារ្យណាអ៊ី!មានអីគេទៀតដេសអ៊ី?

ខ៖ មិនដឹងអីទៀតទេដូចគ្មានទំនុក

ក៖ ចឹងខ្ញុំសូមអរគុណអ៊ី! ច្រើនដែលបានលះបង់ពេលវេលាអោយខ្ញុំធ្វើការសម្ភាស!

ខ៖ ចាស!

ក៖
ចឹងខ្ញុំសូមថតរូបរបស់អ៊ីនិងបទសម្ភាសហ្នឹងគេយកទៅដាក់នៅសាលាវិទ្យាល័យBYUនៅUSA

ខ៖ចឹងហេស ចាស!

ក៖ចឹងជាចុងក្រោយសូមជូនពរអ៊ីអោយមានអាយុវណ្ណៈសុខៈពលៈកុំម្បីឃ្លានឃ្លាតឡើយ។

ខ៖ ចាសអរគុណច្រើន!

ក៖ ចាសអរគុណច្រើនណាអ៊ី!

ខ៖ ចាស!